# សំណុំរឿង ០០២/០២

## ព័ត៌មានសង្ខេប

សំណុំរឿង ០០២/០២ គឺជាការជំនុំជម្រះទីពីរនៅក្នុងសំណុំរឿង ០០២ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលជាទូទៅ ហៅថា សាលាក្តីខ្មែរក្រហម។ ខៀវ សំផន និង នួន ជា គឺជាជនជាប់ចោទនៅក្នុងសំណុំរឿងនេះ។ ការជំនុំជម្រះក្តីនៃសំណុំរឿង ០០២/០២ បានចាប់ផ្តើម នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤។

---

### សាក្សីកម្មចំនួន ១៨៥ នាក់

អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្ម៖

សាក្សីចំនួន ១១៤ នាក់

ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៣ នាក់

និង អ្នកជំនាញចំនួន ៨ នាក់ ។

មាន

សវនាការចំនួន

**២៧៤ ថ្ងៃ**

### ៧៧.៩៣១ នាក់

បានចូលរួមសវនាការ។ អ្នកចូលរួមទាំងនោះមាន សាធារណជន មន្ត្រីរាជរដ្ឋាភិបាល អ្នកការទូត អ្នកសារព័ត៌មាន តំណាងអង្គការក្រៅរដ្ឋាភិបាល និង ដើមបណ្តឹងរដ្ឋប្បវេណី។

---



### ខៀវ សំផន

- កើតនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៣១ នៅខេត្តស្វាយរៀង
- សិក្សានៅប្រទេសបារាំង និងបោះពុម្ពផ្សាយនិក្ខេបបទពីការសិក្សាថ្នាក់បណ្ឌិតរបស់គាត់ ដែលមានចំណងជើងថា "សេដ្ឋកិច្ចប្រទេសកម្ពុជា និងបញ្ហាឧស្សាហូបនីយកម្ម"។
- អតីតប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ
- ចាប់ខ្លួន នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ ២០០៧

### តើមានការចោទប្រកាន់អ្វីខ្លះ?

ការចោទប្រកាន់ក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងការចោទប្រកាន់ពី ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញា ទីក្រុងហ្សឺណែវ ដោយផ្អែកលើការចោទប្រកាន់លើអង្គហេតុ និងទីតាំងឧក្រិដ្ឋកម្ម ដូចខាងក្រោម:

- អំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម (លើកលែងតែមន្ទីរសន្តិសុខក្រូចឆ្មារ) និងជនជាតិវៀតណាម (លើកលែងតែឧក្រិដ្ឋកម្មដែលកងទ័ពបដិវត្តកម្ពុជាបានប្រព្រឹត្តនៅលើទឹកដីវៀតណាម)
- ការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈ
- ការបោសសម្អាតផ្ទៃក្នុង
- មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល
- ការដ្ឋានទំនប់ ១មករា ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្មសហករណ៍ត្រាំកក់
- ការប្រព្រឹត្តិលើពុទ្ធសាសនិក (កម្រិតត្រឹមសហករណ៍ត្រាំកក់) និង
- ការប្រព្រឹត្តិលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ (កម្រិតត្រឹមសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ ១មករា មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់)



### នួន ជា

- កើតថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩២៦ នៅខេត្តបាត់ដំបង
- សិក្សាច្បាប់នៅសាកលវិទ្យាល័យធម្មសាត នៅទីក្រុងបាងកក ប្រទេសថៃ
- អនុលេខាបក្សកុម្មុយនីស្តកម្ពុជា
- ចាប់ខ្លួននៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧

# សេចក្ដីសង្ខេបអំពីទឡ្ហីករណ៍

## សហព្រះរាជអាជ្ញា

សម្រាប់សហព្រះរាជអាជ្ញា នួន ជា និង ខៀវ សំផន ស្ថិតនៅក្នុងចំណោមអ្នកដឹកនាំជាន់ខ្ពស់បំផុតនៃកម្ពុជាប្រជាធិបតេយ្យ ហើយពួកគេម្នាក់ៗ បានចូលរួមយ៉ាងសំខាន់ក្នុងគោលនយោបាយឧក្រិដ្ឋដែលត្រូវបានអនុវត្តទូទាំងប្រទេស។ ប្រជាជនកម្ពុជារាប់លាននាក់ត្រូវបានបង្ខំឲ្យធ្វើការក្នុងលក្ខខណ្ឌអមនុស្សធម៌ ដែលជាការដាក់ឲ្យទៅជាទាសករ នៅតាមសហករណ៍ និងការដ្ឋាន។ ប្រជាជនកម្ពុជាត្រូវបានបង្ខំឲ្យរៀបការ និងរួមដំណេក ដែលផ្ទុយពីឆន្ទៈរបស់ពួកគេ (ដែលជាការរំលោភសេពសន្ថវៈ) ដើម្បីបង្កើនចំនួនប្រជាពលរដ្ឋ។ ពុទ្ធសាសនិក "ប្រជាជនថ្មី" អតីតមន្ត្រីសាធារណរដ្ឋខ្មែរ និងកម្មាភិបាលខ្មែរក្រហមដែលគេសង្ស័យថា មិនស្មោះត្រង់ ហើយជាញឹកញាប់ ប្រជាជនដែលមានទំនាក់ទំនងជាមួយបុគ្គលណាម្នាក់នៅក្នុងប្រភេទមនុស្សទាំងនេះ ត្រូវបានកំណត់ជាគោលដៅដោយរបបកម្ពុជាប្រជាធិបតេយ្យ។ ជនរងគ្រោះទាំងនេះត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ហើយត្រូវបានឃុំឃាំងក្រោមលក្ខខណ្ឌអមនុស្សធម៌ ធ្វើទារុណកម្ម និងសម្លាប់ដោយគ្មានការជំនុំជម្រះ។ ជនជាប់ចោទបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម និងជនជាតិចាម។ គោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យ គឺដំបូងត្រូវបណ្ដេញ បន្ទាប់មកត្រូវសម្លាប់ជនជាតិវៀតណាមទាំងអស់ និងបំផ្លាញក្រុមជនជាតិចាម តាមរយៈសកម្មភាពបន្តបន្ទាប់ រួមទាំងការសម្លាប់ផងដែរ។

## ដើមបណ្ដឹងរដ្ឋប្បវេណី

សម្រាប់សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៦៤ នឹងជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់ធាតុផ្សំសម្ភារនៃបទល្មើសដែលត្រូវបានចោទប្រកាន់។ សហមេធាវីនាំមុខស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តច្បាប់ ពិចារណាទៅលើសំណើរបស់សហព្រះរាជអាជ្ញា ពិចារណាលើភស្តុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នៅពេលកំណត់ថាតើ អំពើដែលត្រូវបានបង្ហាញក្នុងដីកាដំណោះស្រាយ ជាបទល្មើសនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ហើយថាតើ ជនជាប់ចោទបានប្រព្រឹត្តអំពើទាំងនោះដែរឬទេ និងដើម្បីទទួលស្គាល់ព្យសនកម្មដែលដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលរង ដោយសារតែឧក្រិដ្ឋកម្ម ដែលជនជាប់ចោទអាចនឹងត្រូវផ្ដន្ទាទោស។ សហមេធាវីនាំមុខក៏បានដាក់សំណើទាមទារសំណងចុងក្រោយដែលស្នើសុំឲ្យទទួលស្គាល់គម្រោងសំណងចំនួន ១៧ ថាជាការផ្ដល់សំណងតាមផ្លូវតុលាការ ដែលជាប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណី។

## នួន ជា

នួន ជា ទទួលយកការទទួលខុសត្រូវផ្នែកសីលធម៌សម្រាប់ហេតុការណ៍ផ្សេងៗនៃរបបកម្ពុជាប្រជាធិបតេយ្យ។ នួន ជា យល់ថា ដើម្បីយល់ដឹងពីហេតុការណ៍ទាំងនេះ ត្រូវពិចារណាទៅលើមូលហេតុដើមដំបូងនៅមុនឆ្នាំ១៩៧៥ និងផលវិបាកក្រោយឆ្នាំ១៩៧៩។ សម្រាប់ នួន ជា មូលហេតុដើមដំបូងគឺ វៀតណាម ដែលបានឈ្លានពានកម្ពុជា និងបង្កប់អ្នកចូលដៃក្នុងបក្សកុម្មុយនីស្តកម្ពុជា ដែលប៉ុនប៉ងផ្ដួលរំលំរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យស្របច្បាប់។ ការទំលាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកដែលធ្វើឲ្យខ្ទេចខ្ទី និងសង្គ្រាមស៊ីវិល ដែលធ្វើឲ្យប្រទេសកម្ពុជាវិនាសហិនហោច ក៏ជាមូលហេតុដើមដំបូងដែរ។ ផលវិបាកចម្បងរបស់កម្ពុជាប្រជាធិបតេយ្យគឺ ការឈ្លានពានប្រទេសកម្ពុជាដោយខុសច្បាប់ពីប្រទេសវៀតណាម។ សម្រាប់ នួន ជា កត្តាទាំងអស់នេះនាំឲ្យមានឥទ្ធិពលយ៉ាងខ្លាំង ក្នុងការកំណត់ទៅលើកម្ពុជាប្រជាធិបតេយ្យនេះ។ មូលហេតុដើមដំបូងទាំងនេះបានធ្វើឲ្យកម្ពុជាស្ថិតនៅក្នុងស្ថានភាពអាសន្នឥតឈប់ឈរ ដែលធ្វើឲ្យមានគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង ០០២/០២ ដោយគោលនយោបាយនេះ មិនត្រឹមតែជាយុត្តិកម្ម ប៉ុន្តែក៏ជាភាពស្របច្បាប់ផងដែរ។ នួន ជា ក៏អះអាងថា សហព្រះរាជអាជ្ញា មិនបានបង្ហាញបទល្មើសដែលត្រូវបានចោទប្រកាន់ ឲ្យហួសពីវិមតិសង្ស័យនៅឡើយទេ ហើយថា សហព្រះរាជអាជ្ញាបានបង្ហាញនូវការបកស្រាយពីហេតុការណ៍របៀបសាមញ្ញខ្លាំងមួយ។

## ខៀវ សំផន

សម្រាប់ ខៀវ សំផន សហព្រះរាជអាជ្ញាព្យាយាមបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាបានតាក់តែង និងអនុវត្តគោលនយោបាយដែលនាំឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដោយមិនបានពិចារណាលើអង្គហេតុ និងសក្ខីកម្ម ដោយអនុលោមតាមវិធាននៃការជំនុំជម្រះដោយយុត្តិធម៌នោះទេ។ នួន ជា អះអាងថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តលើសយុត្តាធិការរបស់ខ្លួន ហើយបានអនុវត្តច្បាប់ដែលមិនមានអត្ថិភាពក្នុងពេលដែលហេតុការណ៍ទាំងនោះបានកើតឡើង និងបានបង្ហាញពីការរំលោភច្បាប់នីតិវិធី និងច្បាប់សារធាតុ ដែលបានកើតឡើងក្នុងអំឡុងពេលនៃការជំនុំជម្រះ។ ខៀវ សំផន ក៏សង្កត់ធ្ងន់លើសារៈសំខាន់នៃជម្លោះប្រដាប់អាវុធជាមួយវៀតណាម ជាពិសេស នៅតាមតំបន់ព្រំដែន។ ខៀវ សំផន បដិសេធគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលបានបង្ហាញ និងចោទជាសំណួរលើភាពជឿបាននៃសាក្សី និងភស្តុតាងដែលបានស្ដាប់។ ជាចុងក្រោយ ខៀវ សំផន បដិសេធការចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍ និងបទល្មើសដទៃទៀតដែលបានចោទប្រកាន់លើរូបលោក ព្រោះបទល្មើសទាំងនេះមិនអាចកំណត់ជាផែនការឧក្រិដ្ឋ ដែលលោកបានចូលរួម ហើយថាលោកមិនដែលមានចេតនាប្រព្រឹត្តបទល្មើសណាមួយឡើយ។